# ការិយាល័យនៃនាយកដ្ឋានផែនការ និងអភិវឌ្ឍន៍ និងអភិវឌ្ឍន៍សេដ្ឋកិច្ចក្រុងឡូវែល
# គោលការណ៍ណែនាំ និងសំណួរចម្លើយអំពីកម្មវិធីផ្តល់ថវិកាជំនួយ
# ផ្នែកភាពធន់សេដ្ឋកិច្ចដែលជាប្រាក់ពីច្បាប់

1. តើកម្មវិធីផ្តល់ប្រាក់ជំនួយផ្នែកភាពធន់សេដ្ឋកិច្ចគឺជាអ្វី?

កម្មវិធីផ្តល់ប្រាក់ជំនួយផ្នែកភាពធន់សេដ្ឋកិច្ចនេះ បើកផ្តល់ឲ្យដល់អាជីវកម្មនៅក្នុងទីក្រុងឡូវែល រដ្ឋម៉ាសាឈូសេត ដែលមានចក្ខុវិស័យសម្រាប់អនាគតរបស់ខ្លួន និងកំពុងស្វះស្វែងរកជំនួយផ្នែកហិរញ្ញវត្ថុ ដើម្បីជួយឲ្យដំណើរការចក្ខុវិស័យនោះ។ កម្មវិធីនេះនឹងផ្តល់មូលនិធិសម្រាប់អាជីវកម្មចម្រុះ ដែលរងផលប៉ះពាល់ដោយសារតែការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩។ សំណើគម្រោងដែលអាចទទួលបានប្រាក់ជំនួយនេះ គឺទាល់តែត្រូវនឹងផ្នែកណាមួយនៃផ្នែកចំនួនបី (ដូចមានកំណត់ក្នុងចំណុចទី ៤ នៃឯកសារនេះ)។ កម្មវិធីនេះបានថវិកាឧបត្ថម្ភពីថ្នាក់ជាតិតាមរយៈច្បាប់ស្តីពីផែនការជួយសង្គ្រោះពលរដ្ឋអាមេរិក (ARPA) និងត្រូវអនុលោតាមបញ្ញត្តិរបស់ជាតិ។ រយៈពេលនៃការដាក់ពាក្យ នឹងចាប់ផ្តើមនៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០២៣ ដោយប្រាក់ជំនួយនោះនឹងត្រូវផ្តល់ក្នុងខែ មិថុនា ឆ្នាំ ២០២៣។ **រយៈពេលនៃការដាក់ពាក្យសុំជាបឋម គឺនឹងចាប់បើករហូតលដល់ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០២៣ វេលាម៉ោង ១២ថ្ងៃត្រង់។**

2. តើនរណាខ្លះ ដែលមានសិទ្ធិដាក់ពាក្យសុំថវិកាជំនួយពីកម្មវិធីនេះ?

អ្នកដាក់ពាក្យសុំត្រូវតែបំពេញតាមលក្ខខណ្ឌតម្រូវទាំងបីខាងក្រោម៖

អាជីវកម្មត្រូវតែស្ថិតក្នុងផ្នែកដែលរងផលប៉ះពាល់ធ្ងន់ធ្ងរ ដូចដែលមានកំណត់នៅក្នុងផ្នែកខាងក្រោម៖

i. ភោជនីយដ្ឋាន និងសេវាម្ហូបអាហារ
ii. សិល្បៈ ការកំសាន្ត និងសេដ្ឋកិច្ចបែបច្នៃប្រឌិត
iii. ទេសចរណ៍ និងការកំសាន្ត
iv. ការថែទាំសុខភាពផ្ទាល់ខ្លួន និងហាងកែសម្ផស្ស
v. សុខុមាលភាព និងការហាត់ប្រាណ
vi. ការថែទាំកុមារ
vii. លក់រាយខ្នាតតូច
viii. របរទើបបើកថ្មីនៅតំបន់ឡូវែល ដូចជាផ្នែក the I-HUB, M2D2, Lowell Makes និង the UTEC Kitchen Incubator ដែលចង់ឲ្យខ្លួនរីកចម្រើន និងស្ថិតក្នុងតំបន់ឡូវែល

b. អ្នកដាក់ពាក្យត្រូវតែជាអ្នករកស៊ីមានប្រវត្តិល្អជាមួយសាលាក្រុងឡូវែល ដូចជាបង់ពន្ធទៀងទាត់ និងមិនបានរំលោភបំពានក្រមសាលាក្រុងអំពីអគារ ឬសុខភាពណាមួយ។

c. អ្នកដាក់ពាក្យត្រូវតែបើកដំណើរការអាជីវកម្មក្នុងក្រុងឡូវែល រដ្ឋម៉ាសាឈូសេត យ៉ាងហោចបានត្រឹមចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២២។

ពាក្យសុំអាចដាក់តាងនាមឲ្យក្រុមធំ ឬដៃគូ។ បើលោកអ្នកតំណាងឲ្យក្រុមអាជីវកម្មមួយ ដែលដាក់ពាក្យសុំជំនួយថវិការួមគ្នា លោកអ្នកត្រូវកំណត់ដៃគូនាំមុខគេណាម្នាក់ ដែលត្រូវទទួលខុសត្រូវក្នុងការដាក់ពាក្យសុំ និងចាត់ចែកប្រាក់ជំនួយ។ សូមកត់សម្គាល់ថា រាល់ដៃគូទាំងអស់ត្រូវតែបំពេញគ្រប់លក្ខខណ្ឌដើម្បីដាក់ពាក្យនេះ។

3. តើនរណាដែលពុំមានសិទ្ធិដាក់ពាក្យសុំជំនួយពីកម្មវិធីនេះ?

a. សាខាអាជីវកម្ម ឬសាខា
b. អាជីវកម្មដែលមិនមែនជាផ្នែកមួយ នៃឧស្សាហកម្មដែលរងផលប៉ះពាល់ធ្ងន់ធ្ងរ (ដូចមានកំណត់ក្នុងចំណុច 2a)។
c. អ្នកដាក់ពាក្យសុំ ដែលមិនមានប្រវត្តិល្អជាមួយសាលាក្រុងឡូវែល រួមទាំងមិនបានបង់ពន្ធ ឬមានបញ្ហារំលោភក្រមអគារ ឬសុខភាព។
d. អ្នកដាក់ពាក្យសុំ ដែលជំពាក់ពន្ធរដ្ឋ និងជាតិ។
e. អ្នកដាក់ពាក្យសុំ ដែលមានទីតាំងនៅក្រៅរង្វង់ដែនដីឡូវែល រដ្ឋម៉ាសាឈូសេត។
f. អាជីវកម្មបើកនៅផ្ទះ។

លើសពីនេះទៅទៀត អាជីវកម្មដែលស្ថិតនៅតំបន់ក្រីក្រ និងតំបន់អ្នករកប្រាក់ចំណូលបានជាមធ្យម ដែលស្ថិតក្នុងក្រុមប្លុកជំរឿន នឹងទទួលបានការយកចិត្តទុកដាក់បន្ថែម ក្នុងដំណើរការពិនិត្យពាក្យសុំ។

4. តើសំណើបែបណាទើបមានសិទ្ធិដាក់បាន?

អ្នកដាក់ពាក្យសុំ ត្រូវជ្រើសរើសយកផ្នែកណាមួយខាងក្រោម៖

a. **ការបង្កើតទីធ្លាសាធារណៈ:** គម្រោងដែលបង្កើតឲ្យមានការចូលរួម និងលើកទឹកចិត្តឲ្យបង្កើតទីធ្លាសាធារណៈ តាមរយៈសិល្បៈសាធារណៈ តំបន់ជួបប្រជុំគ្នា ការកែលម្អជញ្ជាំងអាគារ កិច្ចសហប្រតិបត្តិការជាមួយសិល្បៈករមូលដ្ឋាន ឬផ្នែកពាក់ព័ន្ធដទៃទៀត។ អ្នកដាក់ពាក្យសុំដែលអ្នកជួលអគារ ត្រូវតែមានការឯកភាពពីម្ចាស់អគារ។
b. **ការបង្កើតកម្មវិធី៖** ការរីកចម្រើនស្ថាប័ន តាមរយៈកម្មវិធី ឬសេវាថ្មីៗ។
c. **ទីតាំង និងហេដ្ឋារចនាសម្ព័ន្ធ៖** ការកែលម្អអគារ ឬទីធ្លា ដើម្បីដោះស្រាយបញ្ហាកង្វល់សុខភាពសាធារណៈ (ឧទាហរណ៍ ការដំឡើងរបាំងការពារ ឬការកែលម្អដែលឲ្យមានការរក្សាគម្លាត ឬកែលម្អគុណភាពខ្យល់ចេញចូល) ក្លាយជារឿងដែលធន់នឹងការប្រែប្រួលធាតុអាកាស (ឧទាហរណ៍ ការទប់ទល់នឹងធាតុអកាស ការដំឡើងឧបករណ៍កំដៅ ការដាំដុះរុក្ខជាតិធម្មជាតិ និងការធ្វើជីកំប៉ុស) និង/ឬ ការគាំទ្រដល់ការពង្រីកស្ថាប័ន។ អ្នកដាក់ពាក្យសុំដែលអ្នកជួលអគារ ត្រូវតែមានការឯកភាពពីម្ចាស់អគារ។

5. តើសំណើបែបណាដែលពុំគ្រប់លក្ខខណ្ឌដើម្បីដាក់ពាក្យសុំ?

a. សំណើសុំជំនួយជួយបង់ថ្លៃចំណាយជាប្រចាំ (ឧទាហរណ៍ ថ្លៃជួលអគារ ថ្លៃបង់រំលស់ ថ្លៃទឹកភ្លើង ឬប្រាក់ខែបុគ្គលិក) ឬយកទៅបង់ផ្តាច់បំណុល។
b. សំណើសុំទិញអចលនទ្រព្យ
c. សំណើគាំទ្រកម្មវិធី ឬសេវាដែលមានស្រាប់ រួមទាំងថ្លៃចំណាយលើស ថ្លៃប្រតិបត្តិការ ឬការចំណាយថែទាំ ដែលអាចពន្យារពេលបាន។
d. សំណើសម្រាប់បង់ថ្លៃធ្វើដំណើរសម្រាប់អាជីវកម្ម
e. សំណើសម្រាប់ប្រើប្រាស់ជាប្រយោជន៍បុគ្គលផ្ទាល់ខ្លួន
f. សំណើសុំទូទាត់សងថ្លៃចំណាយអាជីវកម្ម ដែលបានទូទាត់ ឬសងរួច
g. សំណើសម្រាប់គម្រោង ដែលបានចាប់ផ្តើមនៅមុនមានការឯកភាពដោយសាលាក្រុង ឬចប់ក្រោយថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៦។

6. តើខ្ញុំត្រូវធ្វើអ្វីខ្លះ ដើម្បីដាក់ពាក្យសុំ? តើខ្ញុំត្រូវមានឯកសារអ្វីខ្លះដែលត្រូវផ្តល់ជូន?

កម្មវិធីផ្តល់ជំនួយថវិកាសម្រាប់ភាពធន់សេដ្ឋកិច្ចនេះ មានដំណើរការដាក់ពាក្យពីរផ្នែក។

ក្នុងអំឡុងផ្នែកនៃការដាក់ពាក្យបឋម (ពីថ្ងៃទី ១៣ ខែ កុម្ភៈ ដល់ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០២៣) ទម្រង់នៃការដាក់ពាក្យសុំបឋម នឹងមាននៅលើអនឡាញ និងពាក្យសុំបឋមនេះ អាចដាក់បាន។ ពាក្យសុំតាមអនឡាញនេះ នឹងតម្រូវឲ្យដាក់ព័ត៌មានទំនាក់ទំនងអាជីវកម្ម សំណើគម្រោង ថវិកា ការរៀបរាប់ឆ្លើយតប ដែលផ្តល់ឱកាសដល់អ្នកដាក់ពាក្យសុំ ក្នុងការពន្យល់អំពីសំណើគម្រោងរបស់ខ្លួន និងអំពីឯកសារបង់ពន្ធថ្មីៗបំផុតរបស់ខ្លួន។ ពាក្យសុំបឋមនេះ រំពឹងថានឹងត្រូវការពេលប្រមាណមួយម៉ោង ដើម្បីបំពេញ។ នៅចុងខែ មេសា ឆ្នាំ ២០២៣ ក្រោយបានវាយតម្លៃដោយគណៈកម្មាធិការវាយតម្លៃរួចមក អ្នកដាក់ពាក្យសុំដែលត្រូវបានសម្រាំង នឹងត្រូវអញ្ជើញឲ្យបន្តជំហានបន្ទាប់ ទៅដំណាក់កាលដាក់ពាក្យសុំ។

ក្នុងអំឡុងដំណាក់កាលសម្ភាសអ្នកត្រូវបានជ្រើសរើសសម្រាំងចុងក្រោយ (ពីថ្ងៃទី ១៧ ខែ មេសា ដល់ថ្ងៃទី ១៥ ខែ ឧសភា) អ្នកដាក់ពាក្យសុំដែលត្រូវបានជាប់សម្រាំងចុងក្រោយ នឹងត្រូវសម្ភាស ៣០នាទីជាមួយគណៈកម្មាធិការត្រួតពិនិត្យពាក្យសុំ (សម្ភាសដោយបង្ហាញខ្លួនផ្ទាល់ ឬតាមវីដេអូ Zoom ដែលនឹងជម្រាបតាមក្រោយ)។ នេះជាឱកាសសម្រាប់គណៈកម្មាធិការត្រួតពិនិត្យពាក្យសុំ ក្នុងការសួរសំណួរ និងសម្រាប់បេក្ខជនចុងក្រោយ ក្នុងការផ្តល់ព័ត៌មានសំខាន់ អំពីគម្រោងដែលបានស្នើសម្រាប់អាជីវកម្ម និងចែករំលែកព័ត៌មានបន្ថែម ដែលមិនមានបញ្ចូលក្នុងពាក្យសុំបឋមរបស់ពួកគាត់។ ក្នុងដំណាក់កាលនេះ បេក្ខជនចុងក្រោយ នឹងត្រូវផ្តល់ឯកសារមួយចំនួនទៀត ដែលពាក់ព័ន្ធនឹងគម្រោងនេះ ដែលអាចមានប្រយោជន៍សម្រាប់គណៈកម្មាធិការត្រួតពិនិត្យពាក្យសុំនេះ ក្នុងការយល់កាន់តែច្បាស់អំពីគម្រោង ភាពប៉ះពាល់ និងតម្រូវការរបស់អ្នកដាក់ពាក្យសុំ។ ដំណាក់កាលនេះ រួមមានទាំងការបង្ហាញឯកសារជាគ្រោង សម្រង់សម្តី ឬសម្ភារៈដែលពាក់ព័ន្ធនឹងគម្រោង។

សេចក្តីជូនដំណឹងអំពីការផ្តល់ប្រាក់ជំនួយនេះ (ត្រឹមថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០២៣)៖ សេចក្តីជូនដំណឹងអំពីការផ្តល់ជំនួយថវិកានេះ នឹងត្រូវផ្ញើចេញទៅរាល់បេក្ខជនសម្រាំងចុងក្រោយទាំងអស់ដែលត្រូវបានប្រាក់ជំនួយនេះ។ សូមកត់សម្គាល់ថា ឯកសារបន្ថែមទៀត នឹងត្រូវដាក់នៅដំណាក់កាលនេះ រួមទាំង Form W-9 លេខសម្គាល់អាជីវកម្ម និងឯកសារចម្លងវិញ្ញាបនបត្រ/អាជ្ញាប័ណ្ណអាជីវកម្ម/លិខិត 501(c)3

/Form990។ អ្នកដាក់ពាក្យសុំខ្លះ អាចត្រូវផ្តល់ឯកសារបន្ថែម អាស្រ័យទៅលើសំណើរបស់ពួកគាត់។ អ្នកដាក់ពាក្យសុំ នឹងមិនតម្រូវឲ្យឆ្លើយសំណួរអំពីស្ថានភាពសញ្ជាតិ ឬឯកសារអន្តោប្រវេសន៍ណាមួយនោះឡើយ។

7. តើខ្ញុំដាក់ពាក្យសុំនោះយ៉ាងដូចម្តេច?

យើងខ្ញុំលើកទឹកចិត្តឲ្យលោកអ្នកដាក់ពាក្យសុំបឋមតាមអនឡាញ។ លោកអ្នកអាចដាក់ពាក្យសុំនេះតាមអនឡាញកុំឲ្យហួសថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០២៣ វេលាម៉ោង ១២ថ្ងៃត្រង់ នៅតាមគេហទំព័រនេះ Lowellma.gov/1729/ARPA-Funded-Programs។ ពាក្យសុំបឋមនេះ មានជាទម្រង់ក្រដាស ដោយយកបានពីគេហទំព័រនេះ Lowellma.gov/1729/ARPA-Funded-Programs ដែលលោកអ្នកអាចបោះពុម្ពរួចបំពេញវា។ ពាក្យសុំជាក្រដាស ក៏អាចរកបាននៅការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ច នៅក្នុងនាយកដ្ឋានផែនការ និងអភិវឌ្ឍន៍ និងអាចមកយកបាននៅក្នុងម៉ោងធ្វើការទូទៅ*។ អ្នកដាក់ពាក្យសុំ អាចដាក់ពាក្យបានតែមួយប៉ុណ្ណោះ គឺអាចជាពាក្យសុំតាមអនឡាញ ឬដោយដាក់ជាក្រដាស។ ការដាក់ពាក្យដដែលជាន់គ្នា គឺនឹងត្រូវទាត់ចោលទាំងពីរ។

*នាយកដ្ឋានផែនការ និងអភិវឌ្ឍន៍ JFK Civic Center, 50 Arcand Drive, ជាន់ទីពីរ ទូរស័ព្ទលេខ៖ 978-674-4252

*ម៉ោងធ្វើការធម្មតារបស់យើង គឺថ្ងៃ ចន្ទ ពុធ ព្រហស្បតិ៍ ពីម៉ោង ៨ព្រឹក ដល់ម៉ោង ៥ល្ងាច។ ថ្ងៃ អង្គារ ពីម៉ោង ៨ព្រឹក ដល់ម៉ោង ៨យប់។ ថ្ងៃ សុក្រ ពីម៉ោង ៨ព្រឹក ដល់ម៉ោង ១២ថ្ងៃត្រង់។*

8. តើខ្ញុំគួរធ្វើយ៉ាងដូចម្តេច បើខ្ញុំមានចម្ងល់អំពីកម្មវិធីនេះ?

បេក្ខជនដែលចង់ដាក់ពាក្យ នឹងត្រូវអញ្ជើញឲ្យណាត់ជួបមួយ ក្នុងម៉ោងធ្វើការ ដោយកំណត់ពេលវេលាមួយដែលអ្នកដាក់ពាក្យអាចចុះឈ្មោះសម្រាប់ជួបគ្នាផ្ទាល់តាមវីដេអូ Zoom ឬតាមទូរស័ព្ទ ដើម្បីពិភាក្សាពាក្យរកញនាអំពីចម្ងល់ និងគម្រោងជាមួយបុគ្គលិកផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ច។ អ្នកដែលចង់ដាក់ពាក្យសុំ ក៏អាចផ្ញើជាសំណួរតាមអ៊ីម៉េលបានដែរ ដោយផ្ញើទៅកាន់ DoBizinLowell@lowellma.gov។ សូមកត់សម្គាល់ថា បុគ្គលិកអាចស្នើឲ្យរកម៉ោង ដែលស្ថិតក្នុងម៉ោងធ្វើការ ដើម្បីណាត់ជួបគ្នានេះ។

បើអ្នកដាក់ពាក្យសុំ ត្រូវការជំនួយ ក្នុងការបំពេញពាក្យសុំបឋមនេះ ឬឲ្យជួយដើម្បីរកឯកសារដែលពាក់ព័ន្ធណាមួយ ដោយសារតែពិការភាព ខ្វះសេវាអ៊ិនធើណិត រនាំងភាសា ឬបញ្ហាអ្វីផ្សេងទៀត សូមទាក់ទងនាយកដ្ឋានផែនការ និងអភិវឌ្ឍន៍ក្រុងឡូវែលតាមលេខនេះ៖ 978-674-4252។

9. តើខ្ញុំត្រូវធ្វើអ្វីខ្លះ បើខ្ញុំមិនអាចបំពេញពាក្យសុំនេះតាមអនឡាញបាន ដោយសារតែភាពពិការរបស់ខ្ញុំ ដោយខ្វះសេវាអ៊ិនធើណិត រនាំងភាសា ឬមូលហេតុផ្សេងណាមួយ?

បើលោកអ្នកត្រូវការជំនួយ ដើម្បីបំពេញពាក្យសុំនេះ លោកអ្នកអាចទាក់ទងទៅលេខនេះ 978-674-4252 ឬអ៊ីម៉េល DoBizinLowell@lowellma.gov។ សូមប្រាប់ឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទរបស់លោកអ្នក។ បើលោកអ្នកមិនចេះនិយាយភាសាអង់គ្លេស សូមបញ្ជាក់ភាសាណាមួយដែលលោកអ្នកចេះនិយាយ។ យើងខ្ញុំនឹងដោះស្រាយរកអ្នកបកប្រែ និង/ឬសេវាបកប្រែដើម្បីជួយ។ តម្រូវការជំនួយក្នុងការបំពេញពាក្យសុំនេះ

គឺមិនប៉ះពាល់ដល់លទ្ធភាពរបស់លោកអ្នក នៅក្នុងការចូលរួមក្នុងកម្មវិធី ឬ កម្រិតភាពមានសិទ្ធិរបស់លោកអ្នកក្នុងការទទួលបានមូលនិធិនេះនោះឡើយ។

10. តើក្រុមអាជីវកម្មដែលមិនមែនជាសាជីវកម្ម ឬមិនមែនជាអង្គការមិនរកប្រាក់កម្រៃ ដាក់ពាក្យសុំថវិកាជំនួយនេះបានដែរឬទេ?

ទេ។ ដើម្បីទទួលបានមូលនិធិថ្នាក់ជាតិ អ្នកដាក់ពាក្យសុំត្រូវតែជាម្ចាស់ ឬប្រតិបត្តិករនៃអាជីកម្មដែលរកប្រាក់កម្រៃ។ បើលោកអ្នកជាសមាជិកនៃក្រុមអាជីវកម្ម សូមកំណត់រកដៃគូនាំមុខគេណាម្នាក់ ដែលត្រូវទទួលខុសត្រូវក្នុងការចាត់ចែងប្រាក់ជំនួយនេះ។

11. ខ្ញុំជួលកន្លែងដែលជាទីតាំងអាជីវកម្មរបស់ខ្ញុំ។ តើខ្ញុំនៅតែមានសិទ្ធិទទួលបានជំនួយសម្រាប់ទីតាំងដែរឬទេ?

បាទ/ចាស។ រាល់បេក្ខជនសម្រាំងចុងក្រោយ ដែលមានគម្រោងកែប្រែរចនាសម្ព័ន្ធទីតាំងរបស់ខ្លួន នឹងត្រូវបញ្ចូលលិខិតមួយពីម្ចាស់អគារ ដែលផ្តល់ការឯកភាពដោយកែទីតាំងនោះ។

12. អាជីវកម្មរបស់ខ្ញុំបើកនៅផ្ទះ។ តើខ្ញុំអាចដាក់ពាក្យសុំជំនួយថវិកានេះបានដែរឬទេ?

ទេ។ អាជីវកម្មដែលបើកនៅផ្ទះ មិនមានសិទ្ធិដាក់ពាក្យសុំជំនួយ សម្រាប់កម្មវិធីផ្តល់ជំនួយថវិកាភាពធន់ផ្នែកសេដ្ឋកិច្ចនេះបាននោះឡើយ។

13. តើការវាយតម្លៃអ្នកដាក់ពាក្យសុំប្រព្រឹត្តទៅយ៉ាងដូចម្តេច?

គណៈកម្មាធិការត្រួតពិនិត្យពាក្យសុំមួយ ត្រូវបានបង្កើតឡើង ដែលមានសមាជិកពីនាយកដ្ឋានផែនការ និងអភិវឌ្ឍន៍ និងការិយាល័យអ្នកគ្រប់គ្រងទីក្រុង។ ក្រោយរយៈពេលដាក់ពាក្យត្រូវបានបិទបញ្ចប់ គណៈកម្មាធិការនេះ នឹងវាយតម្លៃពាក្យសុំ និងដាក់ពិន្ទុ ដោយឈរលើលក្ខខណ្ឌកំណត់ (សូមមើលឯកសារភ្ជាប់ A)។

ពាក្យសុំដែលបានពិន្ទុខ្ពស់ជាងគេ នឹងត្រូវជ្រើសរើសសម្រាប់ជុំត្រួតពិនិត្យចុងក្រោយមួយ ដែលនឹងវាយតម្លៃដោយផ្អែកលើលក្ខខណ្ឌខាងក្រោម៖

a. កិច្ចសម្ភាសន៍៖ អ្នកដាក់ពាក្យសុំ ផ្តល់ចម្លើយពូកែៗ ដែលបញ្ជាក់ច្បាស់ៗអំពីគោលបំណងនៃគម្រោងរបស់ខ្លួន និងផ្តល់ភ័ស្តុតាងអំពីសមត្ថភាព ក្នុងការអនុវត្តគម្រោងដូចបានពិពណ៌នា។
b. ការស្រាវជ្រាវ/ផលប៉ះពាល់៖ អ្នកដាក់ពាក្យសុំ បានស្រាវជ្រាវដើម្បីកំណត់អំពីថ្លៃ និងពេលវេលាកំណត់សមស្រប។ បើអាចធ្វើទៅបាន អ្នកដាក់ពាក្យសុំ ត្រូវមានការឯកភាពពីម្ចាស់ផ្ទះ និង/ឬក្រុមប្រឹក្សាគណៈនាយក ដើម្បីអនុវត្តគម្រោងនេះ។

14. តើអ្នកដាក់ពាក្យសុំនឹងទទួលបានប្រាក់ជំនួយឬទេ?

អ្នកដាក់ពាក្យសុំ ទំនងជាមិនទទួលបានប្រាក់ជំនួយនោះទេ។ នេះជាកម្មវិធីប្រកួតប្រជែងសុំជំនួយថវិកា និងការដាក់ពាក្យសុំណាមួយ មិនមែនជាការធានាថាអ្នកដាក់ពាក្យសុំនឹងទទួលបានជំនួយជាថវិកានោះឡើយ។ យើងគិតថា មានអាជីវកម្ម ២០ ដែលនឹងទទួលបានជំនួយថវិកានេះ។

សាលាក្រុងរក្សាសិទ្ធិក្នុងការផ្តល់ប្រាក់ជំនួយទៅអាជីវកម្មណាមួយ ជាចំនួនទឹកប្រាក់ច្រើនជាង ឬតិចជាងអ្វីដែលបានស្នើសុំ ដោយផ្អែកលើព័ត៌មានដែលបានផ្តល់ជូនក្នុងដំណាក់កាលដាក់ពាក្យសុំ។

15. តើជំនួយប្រភេទអ្វីដែលខ្ញុំនឹងទទួលបាន? តើខ្ញុំត្រូវការសងប្រាក់នេះវិញដែរឬទេ?

ជំនួយនេះជាទម្រង់ថវិកា។ លោកអ្នកមិនចាំបាច់សងវិញ ឬបង្វិលប្រាក់ជំនួយនេះមកវិញទេ លើកលែងតែមានការរំលោភបំពានកិច្ចព្រមព្រៀងណាមួយអំពីជំនួយថវិកានេះ។

16. តើជំនួយថវិកានេះមានទំហំប៉ុនណា?

កម្មវិធីផ្តល់ថវិកាជំនួយផ្នែកភាពធន់នៃសេដ្ឋកិច្ចនេះ នឹងដកប្រាក់ពីកញ្ចប់ថវិកាចំនួន $750,000 ដើម្បីផ្តល់ជូនអាជីវកម្មដែលបំពេញគ្រប់លក្ខខណ្ឌ និងដែលបានដាក់សំណើសុំគម្រោង ឬកម្មវិធីដែលដោះស្រាយផលប៉ះពាល់ដែលពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ ទៅលើអាជីវកម្មរបស់ខ្លួន។ សំណើសុំជំនួយថវិកានេះ មិនថាសុំទឹកប្រាក់ចំនួនប៉ុណ្ណានោះឡើយ គឺយើងនឹងពិចារណាទាំងអស់។

17. តើមានតម្រូវការឲ្យធ្វើរបាយការណ៍អ្វីដែរឬទេ?

បាទ/ចាស អ្នកទទួលបានជំនួយថវិកានេះ នឹងត្រូវផ្តល់របាយការណ៍ប្រចាំត្រីមាស (ថ្ងៃទី ៣១ ខែ មីនា ថ្ងៃទី ៣០ ខែ មិថុនា ថ្ងៃទី ៣០ ខែ កញ្ញា និងថ្ងៃទី ៣១ ខែ ធ្នូ) សម្រាប់រយៈពេលនៃការចំណាយ ដែលរបាយការណ៍ដំបូងត្រូវដាក់នៅខែ កញ្ញា ឆ្នាំ ២០២៣។ ទម្រង់គំរូសម្រាប់របាយការណ៍ប្រចាំបីខែម្តងនេះ នឹងមានផ្តល់ជូន។ សាលាក្រុងឡូវែល អាចត្រួតពិនិត្យ និងរៀបចំវាយតម្លៃបន្ថែមទៀត រួមទាំងការពិនិត្យឡើងវិញនូវទិន្នន័យផ្សេងៗ ដែលចាំបាច់ ដើម្បីឈ្វេងយល់អំពីផលប៉ះពាល់នៃថវិកាជំនួយនេះ។

18. តើគម្រោងនេះត្រូវអនុលោមតាមគោលនយោបាយរបស់ក្រុងដែរឬទេ?

បាទ/ចាស គម្រោងនេះត្រូវអនុលោមតាមបទបញ្ជា គោលនយោបាយ និង គោលការណ៍ណែនាំរបស់សាលាក្រុង។ អង្គការដែលត្រូវបានជ្រើសរើស ដើម្បីទទួលបានថវិកាជំនួយនេះ គឺត្រូវអនុលោមតាមរាល់បញ្ញត្តិទាំងអស់របស់មូលដ្ឋាន រដ្ឋ និងជាតិ។

19. តើមាននរណាម្នាក់ដឹងថាខ្ញុំទទួលបានជំនួយថវិកានេះដែរទេ?

បើអាជីវកម្មរបស់លោកអ្នក ត្រូវបានថវិកាជំនួយនេះ សូមចាំថា ឈ្មោះរបស់អ្នកដាក់ពាក្យសុំ គម្រោងដូចបានរៀបរាប់នៅក្នុងពាក្យសុំ និងចំនួនទឹកប្រាក់ដែលត្រូវផ្តល់ជូន នឹងត្រូវបង្ហាញជាសាធារណៈ (មិនបូកបញ្ចូលព័ត៌មានរសើបអំពីបុគ្គល ឬហិរញ្ញវត្ថុ) និងប្រព័ន្ធផ្សព្វផ្សាយ។ រតនាគារជាតិអាមេរិក អាចនឹងទទួលបានព័ត៌មានអំពីជំនួយថវិកានេះផងដែរ។

20. តើកម្មវិធីផ្តល់ជំនួយនេះ បានថវិកាទាំងនេះ មកពីណា?

កម្មវិធីផ្តល់ថវិកាជំនួយសម្រាប់ភាពធនសេដ្ឋកិច្ចនេះ គឺជាផ្នែកមួយនៃក្របខ័ណ្ឌច្បាប់ នៃផែនការសង្គ្រោះពលរដ្ឋអាមេរិករបស់ទីក្រុងឡូវែល ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាក្រុងឡូវែល កាលពីខែ តុលា ឆ្នាំ ២០២២។ ច្បាប់នេះ មានបំណងដោះស្រាយផលប៉ះពាល់ជាអវិជ្ជមានដល់ផ្នែកសុខភាព និង សេដ្ឋកិច្ច ដោយសារតែជំងឺកូវីដ-១៩។ ព័ត៌មានបន្ថែមអំពីក្របខ័ណ្ឌច្បាប់នេះ លោកអ្នកអាចរកបាន។ អាជីវកម្មដែលត្រូវបានសម្រាំង ដើម្បីទទួលបានជំនួយថវិកានេះ គឺត្រូវអនុវត្តតាមច្បាប់មូលដ្ឋាន ច្បាប់រដ្ឋ និង ច្បាប់ជាតិ។

សម្រាប់សំណួរ ឬព័ត៌មានបន្ថែម សូមទាក់ទង៖

City of Lowell
Department of Economic Development
50 Arcand Drive, 2nd Floor
Lowell, MA 01852

DoBizinLowell@Lowellma.gov

DOING BUSINESS IN
#LOWELL
THERE'S A LOT TO like.

| លក្ខខណ្ឌវាយតម្លៃពាក្យសុំបឋម (ពិន្ទុខ្ពស់បំផុត ៣៣) | | | |
|---|---|---|---|
| **មានសិទ្ធិដាក់ពាក្យ** | អ្នកដាក់ពាក្យតំណាងឲ្យឧស្សាហកម្មមួយ ដែលរងផលប៉ះពាល់ខ្លាំង និង ស្ថិតក្នុងទីក្រុងឡូវែល រដ្ឋម៉ាសាឈូសេត និងមានអាជីវកម្ម យ៉ាងហោចណាស់ តាំងពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២២ (មានសិទ្ធិដាក់) | អ្នកដាក់ពាក្យមិន តំណាងឲ្យឧស្សាហកម្មមួយ ដែលរងផលប៉ះពាល់ខ្លាំង និង ស្ថិតក្នុងទីក្រុងឡូវែល រដ្ឋម៉ាសាឈូសេត និងមានអាជីវកម្ម ក្រោយថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២២ និង/ឬជាអាជីវកម្មបើកនៅផ្ទះ (មិនមានសិទ្ធិដាក់) | |
| **សំណើ** | អ្នកដាក់ពាក្យសុំ បានផ្ដល់នូវសំណើមួយ ដែលមានភាពច្បាស់លាស់ និង រៀបរាប់ក្បោះក្បាយ ដែលរួមមានព័ត៌មានលម្អិតផង (៥ ពិន្ទុ) | អ្នកដាក់ពាក្យបានផ្ដល់សំណើមួយ ដែលបានរៀបចំគ្រាន់បើដែរ ប៉ុន្តែខ្វះព័ត៌មានលម្អិត (៣ ពិន្ទុ) | អ្នកដាក់ពាក្យសុំ ដាក់សំណើដែលមិនបានរៀបចំត្រឹមត្រូវ ដែលមិនគួរឲ្យយកមកពិនិត្យ (០ ពិន្ទុ) |
| **ភាពខ្លាំងផ្នែកសារពើពន្ធ** | អ្នកដាក់ពាក្យសុំបានបង្ហាញ ឲ្យឃើញតាមរយៈប្រាក់ចំណូល និង ផែនការ ដែលមានប្រវត្តិល្អ និង ដែលគម្រោងនោះ គឺជាការវិនិយោគល្អ (៣ ពិន្ទុ) | អ្នកដាក់ពាក្យសុំបានបង្ហាញអំពី ប្រាក់ចំណូល និងផែនការរបស់ខ្លួន ដែលមើលទៅគួរឲ្យជឿជាក់ និង ថាការវិនិយោគទំនងល្អដែរ (១ ពិន្ទុ) | អ្នកដាក់ពាក្យសុំមិនបានបង្ហាញអំពី ភាពជឿទុកចិត្ត និងការវិនិយោគ មើលទៅដូចមានហានីភ័យ (០ ពិន្ទុ) |
| **ផលប៉ះពាល់ដោយសារជំងឺកូវីដ** | អ្នកដាក់ពាក្យសុំបានពន្យល់ច្បាស់លាស់ អំពីផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ ទៅលើប្រតិបត្តិការរបស់ខ្លួន (៣ ពិន្ទុ) | អ្នកដាក់ពាក្យសុំបានផ្ដល់ការពន្យល់ខ្លះៗ អំពីផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ លើប្រតិបត្តិការរបស់ខ្លួន ប៉ុន្តែខ្វះភាពច្បាស់លាស់ (១ពិន្ទុ) | អ្នកដាក់ពាក្យសុំមិនបានផ្ដល់សេចក្ដីពន្យល់គ្រប់គ្រាន់ពាក់ព័ន្ធនឹងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ ទៅលើប្រតិបត្តិការរបស់ខ្លួន (០ ពិន្ទុ) |
| **ផែនការស្ដារពីជំងឺកូវីដ-១៩** | អ្នកដាក់ពាក្យសុំ បានផ្ដល់ទិដ្ឋភាពច្បាស់លាស់ អំពីផែនការរបស់ខ្លួន រួមទាំងអំពីរបៀបដោះស្រាយ ផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ និង បានបញ្ជាក់អំពីកិច្ចខិតខំប្រឹងប្រែង ក្នុងការកាត់បន្ថយគ្រោះថ្នាក់ដោយសារជំងឺកូវីដ-១៩ ដែលទាន់សភាពការណ៍ (៣ ពិន្ទុ) | អ្នកដាក់ពាក្យសុំ បានផ្ដល់នូវសេចក្ដីពន្យល់ខ្លះៗ អំពីផែនការស្ដាររបស់ខ្លួន ប៉ុន្តែ មិនបានដោះស្រាយផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ ជាក់លាក់ ឬ ខ្វះភាពច្បាស់លាស់ (១ ពិន្ទុ) | អ្នកដាក់ពាក្យសុំ មានផែនការស្ដារ មិនច្បាស់លាស់ ឬខ្វះសេចក្ដីលម្អិត (០ ពិន្ទុ) |
| **សមត្ថភាព** | អ្នកដាក់ពាក្យសុំ មានភ័ស្តុតាងអំពីសមត្ថភាព ក្នុងការអនុវត្តគម្រោង មិនថាតាមរយៈការប្រើប្រាស់កម្លាំងបុគ្គលិក ដែលមានស្រាប់ ឬការជួលបុគ្គលិកថ្មី ឬ អ្នកពិគ្រោះយោបល់ និង មានធនធានគ្រប់គ្រាន់ (៣ ពិន្ទុ) | អ្នកដាក់ពាក្យសុំមានភ័ស្តុតាងខ្លះៗ អំពីសមត្ថភាព ក្នុងការអនុវត្តគម្រោង ប៉ុន្តែមិនច្បាស់លាស់ ថាតើនឹង មានសមត្ថភាពគ្រប់គ្រាន់ ដើម្បីអនុវត្តគម្រោង ឬអ្នកដាក់ពាក្យសុំ បានបញ្ជាក់អំពីកង្វល់ជុំវិញសមត្ថភាពនេះ (១ ពិន្ទុ) | អ្នកដាក់ពាក្យសុំ ឬពាក្យសុំ បានបញ្ជាក់ថា ពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តគម្រោងឲ្យបានជោគជ័យ (០ ពិន្ទុ) |
| **សមធម៌ និងការរួមបញ្ចូល** | អ្នកដាក់ពាក្យសុំបានពន្យល់ច្បាស់លាស់ អំពីវិធីដែលគម្រោងនេះ នឹងលើកស្ទួយឲ្យមានការចូលរួម និងសមធម៌ នៅក្នុងក្រុងឡូវែល (៣ ពិន្ទុ) | អ្នកដាក់ពាក្យសុំ បានផ្ដល់ការពន្យល់ខ្លះៗ ប៉ុន្តែ ផលប៉ះពាល់ជាវិជ្ជមានលើការរួមបញ្ចូល និងសមធម៌ នៅមានកម្រិត និង មិនច្បាស់ (១ ពិន្ទុ) | គម្រោងមិនបានលើកកម្ពស់ការរួមបញ្ចូល និងសមធម៌នៅទីក្រុងឡូវែល ឬអ្នកដាក់ពាក្យសុំ មិនបានផ្ដល់នូវមូលដ្ឋានណាមួយ ដើម្បីបញ្ជាក់ថាគម្រោងនេះ នឹងលើកស្ទួយការរួមបញ្ចូល និងសមធម៌ (០ ពិន្ទុ) |
| **ភាពធន់** | គម្រោងបានបញ្ជាក់យ៉ាងច្បាស់ អំពីគោលបំណង ក្នុងការ | គម្រោងបញ្ជាក់បំណងលំៗ ក្នុងការលើកកម្ពស់បញ្ហាសុខភាពសាធារណៈ | គម្រោងនេះមិនបានពង្រឹងបញ្ហាសុខភាព សាធារណៈ មិនបានដោះស្រាយ |

| | | | |
|---|---|---|---|
| | ពង្រឹងបញ្ហាកង្វល់ផ្នែកសុខភាពសាធារណៈ: ដោះស្រាយបញ្ហាប្រែប្រួលធាតុអាកាស ឬ លើកស្ទួយ អាជីវកម្ម/លទ្ធភាពមិនរកប្រាក់កម្រៃ ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់ធ្ងន់ធ្ងរ (៣ ពិន្ទុ) | ដោះស្រាយ បញ្ហាប្រែប្រួលធាតុអាកាស ឬកែលម្អ អាជីវកម្ម/លទ្ធភាពមិនរកប្រាក់កម្រៃ ដើម្បីឆ្លើយតបទៅនឹង ផលប៉ះពាល់ធ្ងន់ធ្ងរ ប៉ុន្តែ ពាក្យសុំខ្វះភាពច្បាស់លាស់ (១ ពិន្ទុ) | បញ្ហាប្រែប្រួលអាកាសធាតុ ឬមិនបាន កែលម្អអាជីវកម្ម/លទ្ធភាពមិនរកប្រាក់កម្រៃ ដើម្បីទប់ទល់នឹងផលប៉ះពាល់ធ្ងន់ធ្ងរ (0 ពិន្ទុ) |
| **សេដ្ឋកិច្ចក្នុងមូលដ្ឋាន** | អ្នកដាក់ពាក្យសុំបានពន្យល់ច្បាស់លាស់ និង មានភ័ស្តុតាងបញ្ជាក់អំពីរបៀបដែលគម្រោងនេះ នឹងគាំទ្រដល់សេដ្ឋកិច្ចមូលដ្ឋាន (៣ ពិន្ទុ) | អ្នកដាក់ពាក្យសុំបានផ្តល់តែការពន្យល់ខ្លះៗ ឬមិនច្បាស់លាស់អំពី របៀបដែលគម្រោងនេះ នឹងគាំទ្រ ដល់សេដ្ឋកិច្ចមូលដ្ឋាន (១ ពិន្ទុ) | គម្រោងនេះមិនបានគាំទ្រសេដ្ឋកិច្ចមូលដ្ឋាន (0 ពិន្ទុ) |
| **ថវិកា** | ថវិកាលម្អិតមួយ ត្រូវបានពិចារណាលើរាល់ធាតុផ្សំនៃសំណើគម្រោង ដែលត្រូវបានផ្តល់ជូន (៣ ពិន្ទុ) | ថវិកាមួយត្រូវបានផ្តល់ជូន ប៉ុន្តែវាខ្វះភាពលម្អិត និង/ឬ មិនបានគិតគូដល់ថ្លៃនីមួយៗនៃគម្រោងដែលបានស្នើ (១ ពិន្ទុ) | គម្រោងថវិកាមិនពេញលេញ មិនច្បាស់លាស់ ឬមិនជាក់ស្តែង ដែលបានផ្តល់មក ឬ មិនបានផ្តល់គម្រោងថវិកា (0 ពិន្ទុ) |
| **ពេលវេលាកំណត់** | អ្នកដាក់ពាក្យសុំបានផ្តល់រយៈពេលកំណត់ ដែលចាប់ផ្តើមគម្រោង ត្រឹមថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០២៣ និង បានបញ្ចូលថ្ងៃបិទគម្រោងត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៥ (៣ ពិន្ទុ) | អ្នកដាក់ពាក្យសុំបានផ្តល់នូវរយៈពេល កំណត់ ដែលចាប់ផ្តើមនៅក្រោយខែ សីហា ឆ្នាំ ២០២៣ និង បិទបញ្ចប់នៅត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៥ (១ ពិន្ទុ) | អ្នកដាក់ពាក្យសុំបានផ្តល់នូវរយៈពេលកំណត់ ដែលមិនច្បាស់លាស់ ឬ ដែលមិនបានបញ្ចូលរយៈពេលកំណត់នៃការបិទគម្រោងត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៥ ឬ គ្មានផ្តល់កាលកំណត់ទាល់តែសោះ (0 ពិន្ទុ) |
| **ថែមពិន្ទុ** | អ្នកដាក់ពាក្យសុំមានទីតាំងនៅតំបន់ក្រីក្រ និងអ្នករកបានប្រាក់ចំណូលមធ្យម ក្នុងប្លុកធ្វើជំរឿន (១ ពិន្ទុ) | អ្នកដាក់ពាក្យសុំមិនមានទីតាំងនៅ តំបន់ក្រីក្រ និងអ្នកមានប្រាក់ចំណូល មធ្យមក្នុងតំបន់ជំរឿន (0 ពិន្ទុ) | |